## សេចក្តីបង្រៀនជា

# គោរីជំណោល

# របស់លោកដេរេក ព្រីនស៍

# DEREK PRINCE

**ការការពារប្រឆាំងនឹងការបាក់ទឹកចិត្ត**

ខ្ញុំបានឮលោកប៊ីលី ក្រាហាមនិយាយជាលើកទីមួយកាលគាត់នៅក្នុងទីក្រុងឡុងដ៍នៅឆ្នាំ១៩៥៤។រឿងមួយដែលលោកបាននិយាយនៅក្នុងពេលអធិប្បាយដែលបានធ្វើឲ្យខ្ញុំចាំមិនភ្លេចគាត់បាននិយាយថា"ព្រះជាម្ចាស់មិនដែលប្រើគ្រីស្ទានដែលបាក់ទឹកចិត្តណាម្នាក់ឡើយ"។ ខ្ញុំបានគិតពីពាក្យរបស់លោកម្តងទៀត និង បានសន្និដ្ឋានថាវាពិតជាមិនយុត្តិធម៌ទេ។ការបាក់ទឹកចិត្តគឺពិតជាបញ្ហាមួយដែលខ្ញុំបានកំពុងប្រឈមមុខដោយផ្ទាល់ខ្លួននៅក្នុងពេលនោះហើយខ្ញុំគិតថាវា មិនជាការល្អអីណាស់ណាទេ សម្រាប់គាត់ដែលនិយាយពាក្យអញ្ចឹងនោះ។

គាត់បានលើកឧទាហរណ៍ពីលោកគេឌានដែលបានអង្គុយ នៅពីក្រោយផុងសំរាប់កៀបផ្លែទំពាំងបាយជូរ  កំពុងបោកបែនស្រូវនិងកំពុងលាក់ខ្លួនពីជនជាតិម៉ាឌានដោយការបាក់ទឹកចិត្ត។    ទេវតារបស់ព្រះអម្ចាស់បានបង្ហាញខ្លួនអោយលោកគេឌានឃើញ   ហើយពោលពាក្យដែលនឹកស្មានមិនដល់ថា៖"វិរជនដ៏អង់អាចអើយព្រះអម្ចាស់គង់នៅជាមួយអ្នកហើយ!"(ចៅហ្វាយ៦:១២)។   គេឌានប្រាកដជាបានមើលជុំវិញ      មើលថាតើទេវតាបានកំពុងនិយាយជាមួយនរណាពីព្រោះគាត់បានកំពុងលាក់ខ្លួន     ដោយមានការភ័យខ្លាចចំពោះជនជាតិម៉ាឌាន ។    ព្រះអម្ចាស់ ត្រូវធ្វើការផ្លាស់ប្តូរទស្សនៈរបស់លោកគេឌានជាមុនសិនមុននឹងព្រះអង្គប្រើរូបលោក។ សេចក្តីពិតនេះក៏ សម្រាប់យើងទាំងអស់គ្នាដែរ។ ប្រសិនបើយើង    មិនអាចមើលមកខ្លួនយើងដោយភ្នែកនៃសេចក្តីជំនឿទេនោះយើងពិតជាមិនអាចត្រូវបានជ្រើសតាំងឲ្យបម្រើព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ឡើយ។ ទស្សនៈអវិជ្ជមានខុសមួយពីខ្លួនរបស់យើង   នឹងមិនធ្វើឲ្យយើងអាចសម្រេចបាននូវអ្វី  ដែលព្រះទ្រង់សព្វព្រះហឫទ័យ  ចង់បានពីយើង

នោះទេ ទាល់តែយើងមានទស្សនៈមើលឃើញបែបវិជ្ជមានក្នុងពន្លឺមួយវិញទើបអាចបាន ។ ខ្ញុំចង់ប្រាប់លោកអ្នកអំពីចម្លើយ ដែលមានមូលដ្ឋានមកពីបទព្រះគម្ពីរចំពោះការបាក់ទឹកចិត្ត និង វិធីដោះស្រាយជាមួយនឹងប្រភេទនៃការវាយប្រហារខាងឯវិញ្ញាណ បែបនេះ។

## គ្រឿងសឹកដែលយើងត្រូវការ

នៅក្នុងកណ្ឌគម្ពីរអេភេសូជំពូកទី៦មានបញ្ជីរៀបរាប់ពីគ្រឿងសឹកចំនួន៦: ខ្សែក្រវាត់នៃសេចក្តីពិត អាវក្រោះនៃសេចក្តីសុចរិត ស្បែកជើងនៃដំណឹងល្អអំពីសេចក្តីសុខសាន្តខែលនៃ សេចក្តីជំនឿ មួកដែកនៃសេចក្តីសង្គ្រោះ និងដាវនៃព្រះវិញ្ញាណ។ គ្រឿងសឹកទាំងនេះមិនមែនគ្រាន់តែមានឈ្មោះល្អ ឬជាការបកស្រាយខាងទេវវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាសេចក្តីពិតដែលមានការអនុវត្តន៍ជាក់ស្តែងដែលយើងម្នាក់ៗ ត្រូវការចាប់យកមកបំពាក់ខ្លួនឲ្យបានគ្រប់ៗគ្នា។ ខ្ញុំគ្រាន់តែចង់យកគ្រឿងសឹកចំនួន ២ ពីក្នុងចំណោម

គ្រឿងសឹកទាំង ៦ នេះដើម្បីផ្តល់ជាសេចក្តីបង្រៀនបែប
អនុវត្តន៍ ទៅតាមចំណុចជាក់លាក់ដែលបានដកស្រង់យក
មកពីបទព្រះគម្ពីរ ពីវិធីតទល់យកឈ្នះលើការវាយប្រហារ
យ៉ាងខ្លាំងពីការបំបាក់ទឹកចិត្តខាងឯវិញ្ញាណ។
*១២ ដ្បិតយើងរាល់គ្នាមិនមែន តយុទ្ធនឹងសាច់ឈាមទេ គឺ និង
ពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅ
លោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ
នៅស្ថានដ៏ខ្ពស់ដែរ ១៣ ហេតុ នោះបានជាត្រូវឲ្យយកគ្រប់គ្រឿង
សឹករបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់
បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែ
ឈរមាំមួនដដែល ១៤ ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់
សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីសុចរិតទុកជាប្រដាប់បាំង
ដើមទ្រូង ១៥ ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃ
សេចក្តីសុខសាន្ត ទុកជាស្បែកជើង ១៦ ថែមទាំងយកសេចក្តី
ជំនឿទុកជាខែលផង ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់ទាំង
ព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន ១៧ ចូរ
យកសេចក្តីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ
គឺជាព្រះបន្ទូល ។* ***(អេភេសូ៦:១២-១៧)***

ផ្អែកលើការសិក្សារបស់ខ្ញុំជាច្រើន និង ផ្អែកលើការបកប្រែព្រះគម្ពីរនាសម័យទំនើបជាច្រើន ផងដែរនោះ។ ខ្ញុំជឿជាក់ថាខទី១២ គួរតែត្រូវអានឲ្យត្រឹមត្រូវដូចនេះវិញ: "ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សខាងសាច់ឈាមទេ" នេះងាយយល់ជាង ហើយម្យ៉ាងទៀតអាចនិយាយថា យើងមិនមែនកំពុងតយុទ្ធនឹងមនុស្សលោកទេ ។ យើងមិនមែនតយុទ្ធទល់នឹងម្ដាយក្មេកហើយក៏ មិនមែនតយុទ្ធជាមួយនឹងអ្នកដឹកនាំផ្ដាច់ការដូចជាលោកស្តាឡីន ( Stalin ) ឬលោកហ៊ីត្លែរដែរ ( Hiler) ។

*ដ្បិតយើង មិនមែនតយុទ្ធទល់នឹងមនុស្សខាងសាច់ឈាមទេ គឺតយុទ្ធទល់នឹងមេដឹកនាំនៃអាណាចក្រ ដែលមានសិទ្ធិអំណាចតយុទ្ធប្រឆាំងនឹងអ្នកត្រួតត្រារបស់លោកីយ៍ពីក្នុងភពងងឹត តយុទ្ធប្រឆាំងនឹងកងកម្លាំងខាងវិញ្ញាណដ៏អាក្រក់នៅស្ថានលើ។*

## ចូរប្រើគ្រឿងសឹករបស់ព្រះជាម្ចាស់

សរុបសេចក្ដីមកយើងមានជម្លោះមួយយ៉ាងខ្លាំងពាក់ព័ន្ធជាមួយនឹងបុគ្គលខាងវិញ្ញាណ ដែល យើងមើលមិនឃើញ ជាអ្នកដែលមានអំណាចយ៉ាងខ្លាំង ជាអ្នកគ្រប់គ្រងដ៏ខ្ពស់

និងជាអ្នកដែល ទាស់ប្រឆាំងនឹងយើងទាំងស្រុង និង ចំពោះអ្វីៗគ្រប់យ៉ាងដែលតំណាងអោយព្រះជាម្ចាស់ ហើយ និងចំពោះប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែរ។

ទីបញ្ជាការរបស់ពួកវាគឺស្ថិតនៅស្ថានលើ ហើយពួកវាមាន ជំនាញឯកទេសយ៉ាងប៉ិនប្រសប់ គ្រប់បែបយ៉ាងក្នុងការដាក់ សម្ពាធលើវិញ្ញាណប្រឆាំង នឹងយើងទៅតាមវិធីណាមួយ ដែលពួកវាអាចផ្ដួលយើងបាន។ តាមការសន្និដ្ឋានដ៏សម ហេតុផលមួយពីសេចក្ដីពិតនេះ លោកសាវ័កប៉ូលមានប្រ សាសន៍នៅក្នុងខទី ១៣ ថា " ចូរបងប្អូនប្រើគ្រឿងសស្ត្រាវុធ ទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅ។បើមិនដូច្នេះទេអ្នកនឹងជួប ប្រទះនឹងគ្រោះថ្នាក់ជាមិនខាន។ នេះជាសេចក្ដីសន្និដ្ឋាន ជាក់ស្តែងមួយ ដែលមានភាពសមហេតុផលខ្លាំងណាស់។ ខ្ញុំមិនផ្ដល់អនុសាសន៍ឲ្យ អ្នកដែលចូលរួមក្នុងសង្គ្រាមខាង ព្រលឹងវិញ្ញាណ ឬក្នុងការកសាង ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយគ្មានបំពាក់នូវគ្រឿងសស្ត្រាវុធ របស់ព្រះជាម្ចាស់ជា មុនសិននោះទេ។ ហេតុអ្វី? ពីព្រោះនៅពេលលោកអ្នកវាយ ប្រហារអារក្ស សូមជឿខ្ញុំថាអារក្សនឹងវាយបក មករូបអ្នកវិញ ហើយវាមិនវាយប្រហារលោកអ្នកដោយស្របតាមច្បាប់ទេ។

*ហេតុនោះ បានជាត្រូវឲ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីអោយអ្នករាល់គ្នាអាច នឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន*

*រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែឈរមាំមួនដដែល។(**អេភេសូ៦:១៣**)*

សូមកត់ចំណាំថា លោកប៉ូលសន្មត់ថាជាថ្ងៃអាក្រក់ដែលនឹងត្រូវមកដល់។ ខ្ញុំមិនជឿថា ថ្ងៃនេះសំដៅទៅលើគ្រារងទុក្ខវេទនាយ៉ាងខ្លាំងនោះទេ។ វាមានន័យថាគ្រីស្ទានគ្រប់រូប នឹងឆ្លងកាត់ ថ្ងៃអាក្រក់របស់គេម្នាក់ៗជាពិសេសដោយផ្ទាល់ខ្លួន។ នៅពេលព្រះយេស៊ូមានព្រះបន្ទូលអំពីមនុស្សពីរនាក់ដែលបានសង់ផ្ទះ មនុស្សម្នាក់បានសង់នៅលើផ្ទាំងថ្ម និងម្នាក់ទៀតបានសង់នៅ លើដីខ្សាច់ **(ម៉ាថាយ៧:២៤-២៧)** ព្រះអង្គមិនបានមានព្រះបន្ទូលថា "ប្រសិនបើមានខ្យល់ និង ភ្លៀងបង្អុរចុះមក"។ ព្រះអង្គមានព្រះបន្ទូលថា "*នៅពេលខ្យល់ និង ភ្លៀងបង្អុរចុះមក*"។ ផ្ទះ នីមួយៗត្រូវបានទទួលការសាកល្បងដូចៗគ្នា។ នៅពេលដែលព្រះយេស៊ូបានប្រាប់ប្រស្នាអំពីអ្នកព្រោះគ្រាប់ពូជ ព្រះអង្គមានព្រះបន្ទូលថា "*នៅពេលមានទុក្ខលំបាក និងការបៀតបៀនកើតឡើង*" **(ម៉ាថាយ១៣:២១)**។ ព្រះអង្គមិនបានមានព្រះបន្ទូលថា " ប្រសិនបើ "ព្រះអង្គបានលើកយកប្រស្នាហ្នឹងមកដើម្បីបញ្ជាក់ថា ការបៀតបៀននឹងកើតឡើងមកមែន។ គ្រីស្ទានគ្រប់រូបនឹងត្រូវឆ្លងកាត់ថ្ងៃអាក្រក់នៅពេលនោះ ពួកគេត្រូវតែប្រឈមមុខជាមួយនឹងទុក្ខ

លំបាក និងការបៀតបៀន។ លោកប៉ូលបានមានប្រសាសន៍នៅក្នុង គម្ពីរ**កិច្ចការ ១៤:២២** ថា "*យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីអោយបានចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់"។* គឺគ្មានផ្លូវណាផ្សេងទៀតឡើយ។

ដូច្នេះជាបឋមយើងត្រូវទទួលយកពាក្យថា **នៅពេល** ដោយត្រូវកំណត់ចំណាំយ៉ាងរឹងមាំនៅក្នុងគំនិតរបស់យើង។ ចូរចងចាំថា វាមិនមានអ្វីខុសឆ្គងទេនៅពេលដែលយើងត្រូវឆ្លងកាត់ ថ្ងៃ អាក្រក់ និង ស្ថិតនៅក្នុងសម្ពាធមួយយ៉ាងខ្លាំងនោះ ហើយវាក៏មិនមែនមានន័យថា យើងស្ថិតនៅឆ្ងាយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។

ក្នុងចំណោមគ្រឿងសឹកទាំង៦ក្នុងបញ្ជីដែលលោកប៉ូលមាន ខ្ញុំគ្រាន់តែចង់លើកយកគ្រឿងសឹកចំនួនតែ ២ មកនិយាយប៉ុណ្ណោះគឺ: អាវក្រោះ និងខែល។ គ្រឿងសឹកចំនួន ៤ ទៀតក៏សំខាន់ដែរ ប៉ុន្តែ សម្រាប់គោលបំណងនៃសំបុត្រនេះខ្ញុំចង់ផ្តោតទៅលើតែគ្រឿងសឹកចំនួន ២ តែប៉ុណ្ណោះ។ ខ្ញុំចង់ស្វែងរកមធ្យោបាយក្នុងការអនុវត្តជាក់ស្តែង យ៉ាងសំខាន់មួយចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំអំពីរបៀបប្រើប្រាស់អាវក្រោះ និង ខែល។

## អាវក្រោះ( ដើមទ្រូង )

សូមចាប់ផ្តើមដោយការកត់ចំណាំពីចំណាប់អារម្មណ៍មួយទៅលើបទគម្ពីរដែលមានភាពស្របគ្នាចេញពីគម្ពីរ**អេភេសូជំពូកទី៦** និងគម្ពីរ **១ថែស្សាឡូនីចជំពូកទី ៥**:៨ *តែយើងដែលជាពួកនៃថ្ងៃ យើងត្រូវដឹងខ្លួន ទាំងប្រដាប់កាយដោយសេចក្តីជំនឿនិងសេចក្តីស្រឡាញ់ ទុកជាប្រដាប់បាំងដើមទ្រូង ហើយសេចក្តីសង្ឃឹមរបស់ផងសេចក្តីសង្គ្រោះ ទុកជាមួកសឹក ។**(១ទី៨)***

**អេភេសូ៦:១៤** ថែងថា អាវក្រោះនៃសេចក្តីសុចរិត ប៉ុន្តែ ១ថែស្សាឡូនីចជំពូកទី៥:៨ប្រាប់យើងកាន់តែជាក់លាក់ថែមទៀតពីអ្វីទៅដែលជាសេចក្តីសុចរិត។ វាមិនមែនជាសេចក្តីសុចរិតមកពីការ ខិតខំប្រឹងប្រែងរបស់ខ្លួនឯង ឬក៏មកពីការប្រព្រឹត្តអំពើល្អដែរ ប៉ុន្តែគឺជាសេចក្តីសុចរិតនៃជំនឿដែលធ្វើការប្រព្រឹត្តដោយចិត្តស្រឡាញ់វិញ។ និយាយអញ្ចឹងផ្ទៃរឿងនៃជំនឿនេះគឺជា គ្រឿងសឹកសំខាន់នៅក្នុងចំណោមគ្រឿងសឹកទាំងអស់ហើយក៏ជាសរីរាង្គមួយដ៏សំខាន់របស់រូបកាយដែលសម្រាប់ការពារដែរ ។ តើសរីរាង្គណាមួយនៃរូបកាយដែលដើមទ្រូងធ្វើការការពារ?គឺបេះដូង។ ការការពារបេះដូងគឺជាគោលបំណងរបស់អាវក្រោះ ( ដើមទ្រូង)

នៃសេចក្ដីសុចរិត តាមរយៈជំនឿដែលប្រព្រឹត្តដោយចិត្តស្រឡាញ់។ សូមចងចាំថាជំនឿដែលមានចែងក្នុងបទគម្ពីរគឺតែងតែមាននៅក្នុងចិត្ត មិនមែនមាននៅក្នុងខួរក្បាលទេ។តួយ៉ាងដូចជា **រ៉ូម១០:១០** ចែងថា "ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត"។ ជំនឿពិតប្រាកដមិនមែនគ្រាន់តែជាគំនិតបញ្ញាឬទេវវិទ្យា ហើយក៏មិនមែនជាគោល លទ្ធិអ្វីដែរ។ វាគឺជា ជំនឿមកពីក្នុងចិត្តដែលធ្វើការរួមជាមួយនឹងសេចក្ដីស្រឡាញ់។ ភ្ជាប់ជាមួយគ្នានេះ សូមមើលគម្ពីរ**កាឡាទី៥:៦**

*ពីព្រោះក្នុងព្រះគ្រីស្ទយេស៊ូ ដែលកាត់ស្បែកឬមិនកាត់ នោះមិនជាប្រយោជន៍អ្វីទេ មានប្រយោជន៍តែសេចក្តីជំនឿ ដែលប្រព្រឹត្តដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ។*

នេះគឺជា សេចក្ដីថ្លែងមួយដ៏សាមញ្ញដែលមិនពិបាកយល់។ យើងត្រូវរំលឹកខ្លួនយើងជាប់ជានិច្ចថា រឿងមួយដែលពិតជា

សំខាន់ចំពោះជីវិតគ្រីស្ទានទាំងមូលនោះគឺជា ជំនឿដែលប្រព្រឹត្តដោយចិត្តស្រឡាញ់។ យើងអាចទទួលបានចម្លើយដែលមានហេតុផលឈ្លាសវៃជាច្រើន ពីសំនួរទេវវិទ្យាគ្រប់ប្រភេទទាំងអស់នេះ ហើយគ្រាន់តែយើងខកខានមិនបាន

ទទួលសេចក្ដីពិត ជាស្នូលមួយដ៏ សំខាន់នោះ គឺជាចិត្តដែលមានជំនឿ ធ្វើការប្រព្រឹត្តដោយសេចក្ដីស្រឡាញ់ ហើយបើគ្មានសេចក្ដីពិតបែបនេះទេ លោកអ្នកដូចជា មិនបានទទួលអ្វីទាំងអស់។

អាវក្រោះ (ដើមទ្រូង) ដែលការពារបេះដូង (ចិត្ត) គឺជាជំនឿដែលប្រព្រឹត្តដោយចិត្តស្រឡាញ់។

នៅពេលគេវះយកដើមទ្រូងចេញ នោះសរីរាង្គដែលសំខាន់ ហើយងាយនឹងខូចជាងគេបំផុតនោះគឺបេះដូងដែលត្រូវបាន លេចចេញមក។ ទាក់ទងនឹងធម្មជាតិនៃសេចក្ដីជំនឿយើង ត្រូវដឹងថា វាតែងតែទាក់ទងទៅនឹងអ្វីៗដែលមើលមិនឃើញ មិនដែលមើលឃើញសោះ។ ដូចជានៅក្នុងគម្ពីរ **២កូរិនថូស ៥:៧** *ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ″ៗ* **ដើរ** មានន័យថា ‶ រស់នៅ ″។

ជីវិតទាំងមូលរបស់យើងជាគ្រីស្ទានមិនមានមូលដ្ឋានទៅលើ អ្វីដែលយើងមើលឃើញនោះទេ ប៉ុន្តែ មានមូលដ្ឋានលើអ្វី ដែលយើងជឿវិញ ។ ដោយមានជំនឿ មិនមែនដោយមើល ឃើញទេ ហើយបើយើងត្រឡប់ការទាំងពីរនេះបញ្ច្រាសគ្នាវិញ ប្រសិន បើយើងដើរដោយអ្វីដែលយើងមើលឃើញនោះ យើងនឹងមិនដើរដោយអ្វីដែលយើងជឿទេ។

បញ្ហាទាំងមូលនេះគឺជាកំហុសដំបូងបំផុតដែលមនុស្សជាតិ

បានធ្វើ។ នៅពេលសត្វពស់នៅក្នុងសួនអេដែន បានសួរពី ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអេវ៉ាបានកំសាន្តលេងជាមួយនឹងសំនួរនោះ។នាងក៏បានទទួលបរាជ័យ **លោកុប្បត្តិ ៣:៦** ប្រាប់យើងពីអ្វីដែលជាសម្ពាធបាននាំឲ្យអេវ៉ាឆ្លើយតប:"*ស្ត្រីមើលទៅដើមឈើឃើញថាមានរសជាតិឆ្ងាញ់ពិសា" ។* មានពាក្យគន្លឹះមួយគឺឃើញ ។ អេវ៉ាបានចាកចេញពីអាណាចក្រនៃជំនឿ លើពាក្យដែលមើលមិនឃើញទៅទុកចិត្តលើការមើលឃើញរបស់នាងវិញ ។ មួយរំពេចភ្លាមនោះ នាងក៏បានចាញ់ការល្បួង។ គោលការណ៍ ដូចគ្នានេះក៏អនុវត្តចំពោះយើងដែរ។ នៅពេលយើងដើរដោយអ្វីដែលយើងមើលឃើញ នោះយើងមិនសមនឹងធ្វើការប្រកួតជាមួយអារក្សទេ។យើងត្រូវតែដើរដោយមានជំនឿ មិនមែនដោយ មើលឃើញឡើយ។

អាវក្រោះដែលការពារចិត្តរបស់យើងគឺជា ជំនឿលើព្រះជាម្ចាស់ដែលមើលមិនឃើញ និងលើព្រះ បន្ទូលរបស់ទ្រង់ ហើយជំនឿនេះធ្វើការប្រព្រឹត្តដោយចិត្តស្រឡាញ់។ ពេលយើងបោះបង់ជំនឿបែបនេះចោល យើងលែងមានសេចក្តីស្រឡាញ់ដ៏ពិតប្រាកដទៀតហើយ។ មនុស្សខ្លះនិយាយថា " សេចក្តីស្រឡាញ់គឺសំខាន់ជាងសេចក្តីជំនឿ"។

នេះអាចមានតែវិធីតែមួយគត់ គឺស្រឡាញ់ ដោយជំនឿ។ ចាប់តាំងពីជំនឿធ្វើការតាមរយៈសេចក្តីស្រឡាញ់មកវាគ្មានអ្វីឆ្ងល់នោះទេ នៅ ពេលដែលយើងដាក់អាវក្រោះនេះចុះ យើងប្រាកដជាមានចិត្តឆាប់ខឹង ខកចិត្ត អន្ទះអន្ទែងហើយមានភាពមួម៉ៅដាក់ប្តីប្រពន្ធរបស់យើងជាមិនខាន។ ជំនឿរបស់យើងគឺជាអ្វីតែមួយគត់ដែលអាចផលិតនូវសេចក្តីស្រឡាញ់ចេញបាន។ ហេតុដូច្នេះហើយ បានជានៅតែមានបុរសចាស់ដែលមានចរិកកាចអាក្រក់និងចម្លែក ប៉ុន្តែ អ្វីទៅជាឫសគល់នៃបញ្ហានោះ? អាវក្រោះត្រូវបានដាក់ចុះ។

## ខែល

បើអាវក្រោះការពារបេះដូង ដូច្នេះខែលការពាររូបកាយទាំងមូលរបស់មនុស្ស ។ នៅក្នុងសម័យរ៉ូម៉ាំងប្រសិនបើអ្នកបានចេះពីរបៀបកាន់ខែលនោះ គ្មានផ្នែកណាមួយនៃរូបកាយរបស់អ្នកអាចប៉ះត្រូវព្រួញភ្លើងដ៏ក្តៅគគុកបានឡើយ។ ដូច្នេះ ជំនឿក៏ធ្វើជាខែលការពារមនុស្សទាំងមូលដូចគ្នាដែរ។ ពេលខ្លះយើងយល់ខុសពីសេចក្តីជំនឿគិតថាវាជាអ្វីដែលយើងដឹងខ្លួនឯងថា ត្រូវធ្វើគ្រប់ពេលវេលា។ ‟ ខ្ញុំត្រូវតែបង្ហាញ សមត្ថភាពខាងព្រលឹងវិញ្ញាណរបស់ខ្ញុំហើយជឿ″។ប៉ុន្តែសេចក្តីជំនឿ ពុំបានទាមទារសកម្មភាពជា

ច្រើននោះទេព្រោះវាជាឥរិយាបទនៃការជឿទុកចិត្តលើព្រះជាម្ចាស់វិញ។

ប្រពន្ធក្រោយរបស់ខ្ញុំលីឌាបានលើកឧទាហរណ៍មួយពីក្មេងប្រុសតូចម្នាក់ ដែលឪពុករបស់វាបីនៅក្នុងដៃរបស់គាត់។ ក្មេងប្រុសតូចបានខំប្រឹងកាន់កអាវឪពុករបស់វាយ៉ាងណែន ដើម្បីកុំអោយវាធ្លាក់ចុះ ប៉ុន្តែ មិនយូរប៉ុន្មានវាក៏ងងុយគេង ហើយដេកលក់ទៅ ។ ដៃរបស់វាបានសម្រាក ប៉ុន្តែដៃរបស់ឪពុកវានៅតែកាន់បីវាយ៉ាងជាប់។តាមពិតក្មេងប្រុសតូចហ្នឹងពុំចាំបាច់ខំប្រឹងកាន់កអាវឪពុករបស់វានោះទេ។ នេះដូចជាយើងជាមួយនឹងព្រះជាម្ចាស់ដែរ យើងអាចកាន់ជាប់ ប៉ុន្តែ ទោះបីពេលដែលយើងលែងកាន់ក៏ដោយក៏ព្រះជាម្ចាស់នៅតែកាន់បីយើងយ៉ាងជាប់ដែរ។

តាមការពិតយើងអាចសម្រាកបាន ។ សេចក្តីជំនឿគឺមិនមែនជាការខិតខំប្រឹងប្រែង ដោយកាន់ព្រះជាម្ចាស់ជាប់ឥតលែងខ្លាចក្រែងទ្រង់ចេញទៅឆ្ងាយបាត់នោះទេ ផ្ទុយទៅវិញវាជាឥរិយាបទមួយដែលគ្រាន់តែដឹងថាទ្រង់មានវត្តមានគង់នៅទីនេះ ហើយយើងស្ថិតក្នុងព្រះហស្តដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់។ស្របទៅនឹងឥរិយាបទនេះក៏មានជាការអះអាងមួយពីសេចក្តីជំនឿដែល លោកអ្នកមានដែរ។

លោកអ្នកប្រហែលជាធ្លាប់បានឮពីពាក្យបីម៉ាត់ដែលជា

សេចក្តីបង្រៀនដ៏ សាមញ្ញមួយ ពាក្យទាំងបីម៉ាត់នោះគឺ: សេចក្តីពិត ជំនឿ និងអារម្មណ៍ តាមលំដាប់លំដោយ។ សេចក្តីពិតគឺ ស្ថិតនៅក្នុងព្រះគម្ពីរ ជំនឿបញ្ជាក់ពីសេចក្តីពិតទាំងនោះ ហើយអារម្មណ៍របស់លោកអ្នកថែរក្សាអារម្មណ៍របស់ខ្លួនឯង។ប៉ុន្តែប្រសិនបើយើងចាប់ផ្តើមជាមួយនឹងអារម្មណ៍ របស់យើងនោះ យើងក៏នឹងមិនមានស្ថេរភាពទៅតាមអារម្មណ៍ដែរ។ សេចក្តីពិត មិនដែលផ្លាស់ ប្តូរ ប៉ុន្តែអារម្មណ៍គឺប្រែប្រួលពីពេលមួយទៅពេលមួយជានិច្ច។ យើងមិនអាចដាក់មូលដ្ឋានគ្រឹះ នៃជំនឿរបស់យើង ទៅលើអារម្មណ៍របស់យើងបានទេ។ មូលដ្ឋានគ្រឹះនៃជំនឿរបស់លោកអ្នកស្ថិតនៅលើសេចក្តីពិតក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមិនផ្លាស់ប្តូរ ។ សេចក្តីពិត នៅតែជាសេចក្តីពិតដដែល ពីមួយម៉ោងទៅមួយម៉ោង ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ។ពាក្យថាជឿគឺតម្រូវឲ្យមានការសម្រេចចិត្តពីខាងក្នុងចិត្តមក ។ លោកស្មីតវីហ្គលស្វត បានមានប្រសាសន៍ថា "ខ្ញុំមិនដែលផ្លាស់ប្តូរទៅតាមអារម្មណ៍របស់ខ្ញុំនោះទេ ខ្ញុំគ្រាន់តែបានផ្លាស់ប្តូរទៅតាមអ្វីដែលខ្ញុំជឿប៉ុណ្ណោះ"។

ភាពអចិន្ត្រៃយ៍តែមួយគត់មិនផ្លាស់ប្តូរជាប្រភពនៃសេចក្តីពិត ដែលមានសុពលភាពនោះ គឺ ព្រះគម្ពីរ។

សេចក្ដីជំនឿបាននិយាយថា: "ព្រះគម្ពីរគឺជាសេចក្ដីពិត ហើយខ្ញុំជឿលើព្រះគម្ពីរ។ ព្រះជាម្ចាស់គង់នៅទីនេះ។ ទ្រង់នឹងមិនអនុញ្ញាតឱ្យខ្ញុំចេញទៅទេ។អារម្មណ៍របស់ខ្ញុំអាចថែរក្សា ខ្លួនឯងបាន"។ ប្រសិនបើលោកអ្នកមានឥរិយាបទបែបនេះ អារម្មណ៍របស់លោកអ្នកនឹងនាំអ្នកឲ្យដើរតាមសេចក្ដីពិត។ប៉ុន្តែប្រសិនបើអ្នកចាប់ផ្តើមជាមួយនឹងអារម្មណ៍របស់អ្នក នោះអ្នកនឹងមិន ទទួលបាននូវសេចក្ដីពិតទេ។ វាជាអាទិភាពដាច់ខាតមួយដែលអ្នកត្រូវតែចាប់ផ្តើមជាមួយនឹង សេចក្ដីពិតនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។

## ការស្គាល់សេចក្ដីពិត

ដើម្បីធ្វើដូចនោះបាន លោកអ្នកត្រូវស្គាល់សេចក្ដីពិត។ លោកអ្នកត្រូវតែដឹងពីសេចក្ដីពិតដែលបទគម្ពីរនិយាយ។

ឧទាហរណ៍ សេចក្ដីពិតពីកាប្រោសលោះរបស់យើង។ ពាក្យថាប្រោសលោះមានន័យថា"ទិញ យកមកវិញ" បទគម្ពីរនិយាយថាយើងត្រូវបានលក់នៅក្រោមអំណាចបាបនៅក្នុងទីផ្សារទាសកររបស់អារក្សសាតាំង ប៉ុន្តែ ព្រះយេស៊ូ

បានប្រោសលោះយើង ឬទិញយើងយកមកវិញ ចេញពីទីផ្សារទាសកររបស់អារក្សសាតាំង ដោយព្រះលោហិតដ៏ថ្លៃ

វិសេសរបស់ទ្រង់ ។ តើបទគម្ពីរណាមួយដែលនិយាយពីសេចក្តីពិតនេះ? **ទំនុកដំកើងជំពូក ១០៧ : ២** និយាយថា *"គួរឲ្យពួកអ្នកដែល ព្រះយេហូវ៉ាបានប្រោសលោះបានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះឲ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវនោះ"។*

ព្រះអម្ចាស់បានរំដោះយើង ដូច្នេះយើងមិនស្ថិតនៅក្នុងកណ្តាប់ដៃរបស់សត្រូវទៀតទេ ប៉ុន្តែ ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអង្គវិញ។ បន្ទាប់មកសូមពិនិត្យមើល **កូឡុស១:១២-១៤** *ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឲ្យយើងបានគួរ នឹងទទួលចំណែកកេរ្តិ៍អាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង ១៣ ទ្រង់បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ ១៤ យើងរាល់គ្នាមានសេចក្តីប្រោសលោះក្នុងព្រះរាជបុត្រានោះ គឺជាសេចក្តីផ្ចាច់បាប ដោយសារព្រះលោហិតទ្រង់ ។*

ជាការពិត ព្រះជាម្ចាស់បានរំដោះយើងចេញពីអំណាចនៃសេចក្តីងងឹត-នគររបស់អារក្សសាតាំងហើយចម្លងយើងចូលក្នុងព្រះរាជ្យរបស់ព្រះគ្រិស្ត ។ ដូច្នេះយើងទទួលបានការ

ប្រោសលោះ ហើយបាបរបស់យើងត្រូវបានអត់ទោស។ យើងមិនស្ថិតនៅក្នុងដែនដី របស់អារក្សសាតាំងហើយក៏មិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់វាដែរ។អ្នកមិនជឿអ្នកដែលបដិសេធព្រះគ្រិស្ត ដែលបះបោរ និងមិនស្តាប់បង្គាប់ព្រះអង្គគឺស្ថិតនៅក្រោមសិទ្ធិអំណាចស្របច្បាប់របស់អារក្សសាតាំងប៉ុន្តែយើងមិនស្ថិតក្រោមសិទ្ធិអំណាចរបស់វាទេ។

សេចក្តីពិតគឺថា នៅពេលដែលយើងបានប្រែចិត្តហើយបានចុះចូលចំពោះព្រះយេស៊ូគ្រិស្តនិងបានទទួលទ្រង់ធ្វើជាព្រះអម្ចាស់ យើងត្រូវបានព្រះអង្គចម្លងទាំង ព្រលឹងវិញ្ញាណនិងរូបកាយចេញពីនគររបស់អារក្សសាតាំងចូលមកក្នុងព្រះរាជ្យរបស់ព្រះគ្រិស្តវិញ។ ទាំងនេះគឺជាសេចក្តីពិត។ យើងជឿលើសេចក្តីពិតមកពីអាណាចក្រនៃព្រះបន្ទូលរបស់ព្រះអង្គដែលមើលមិនឃើញពីព្រោះ យើងមិនដើរដោយប្រើអារម្មណ៍របស់យើងទៀតទេ។ ខែលនៃជំនឿនេះគ្របបាំងការពារជីវិតរបស់យើងនៅគ្រប់កន្លែងទាំងអស់។

គ្មានព្រួញភ្លើងណាមួយ អាចគេចផុតពីខែលនេះមកប៉ះនឹងយើងបានឡើយ។យើងឃើញថាព្រះជាម្ចាស់បានប្រទានឲ្យយើងនូវខែលការពារ ដែលមានប្រសិទ្ធិភាពនៅពេលដែល

សត្រូវព្យាយាមបំបាក់ទឹកចិត្តយើង។នៅពេលដែលយើងចង ចាំបាន ដោយរៀបចំខ្លួនរបស់ យើងជារៀងរាល់ថ្ងៃ ដោយពាក់គ្រឿងសឹកទាំងពីរនេះ ( ហើយរួមទាំងគ្រឿងសឹក ប្ញូនផ្សេងទៀត នោះ ) ដើម្បីការការពារប្រឆាំងនឹងការវាយ ប្រហារ ដែលនឹងមកដល់ជាមិនខាន នោះយើងនឹង ឃើញថាព្រះជាម្ចាស់ទ្រង់ស្មោះត្រង់ នឹងពង្រឹងសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមរបស់យើងដោយប្រទានឱ្យយើងអាចឈរ ទទួលជ័យជម្នះបាន រួមជាមួយព្រះវិញ្ញាណរបស់ទ្រង់។

**ដកស្រង់ចេញពីទស្សនាវដ្ដី**
**"ស្រាទំពាំងបាយជូរថ្មី" ខែមិថុនា ឆ្នាំ១៩៧៩**

# អង្គការមួយសម្រាប់មួយកម្ពុជា

ពត៌មានបន្ថែម សូមទំនាក់ទំនងមកការិយាល័យយើងខ្ញុំ

តាមរយៈអាស័យដ្ឋាន : ផ្ទះលេខ 38-38 A ផ្លូវ 336 សង្កាត់បឹងសាឡាង

ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរសព្ទ: 023 67 555 86

គេហទំព័រ: www.one2oneworld.org

# អង្គការមួយសម្រាប់មួយកម្ពុជា

## បានទទួលសិទ្ធិ

ក្នុងការប្រែសម្រួលទៅជាភាសាខ្មែរនៅក្នុងការិយាល័យព័ន្ធកិច្ច ដេរេកព្រីន)Derek Prince) ប្រចាំនៅប្រទេសកម្ពុជា តាមរយៈ ព័ន្ធកិច្ចដេរេកព្រីនប្រចាំនៅតំបន់អាស៊ី-ប៉ាស៊ីភិច ទំនាក់ទំនង អាស័យដ្ឋាន ផ្លូវ ហាដុន 38 ប្រអប់សំបុត្រ 2029ព្រ,ះវិហារព្រះ គ្រិស្ត 8140, ប្រទេសណូវែសឺឡង់

**ទូរសព្ទ : ០០៦៤ ៣ ៣៦៦ ៤៤៣**

**ទូរសារ : ០០៦៤ ៣ ៣ ៣៦៦ ១៥៦០**

**អ៊ីម៉ែល** admin@dpm.co.nz

**គេហទំព័រ** www.dpm.co.nz